**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០២/០១២ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខជស/រកម/០១៩៥/04 ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៦អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤១អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត **ប្រៃសណីយ៍កម្ពុជា** មានអក្សរកាត់ថា **ប.ក.** ដែលជាភាសាអង់គ្លេស **CAMBODIA POST** មានអក្សរកាត់ថា **C.P.**។

**ប.ក.** ជាសហគ្រាសសាធារណៈ មានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប.ក.** មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ អាសយដ្ឋាន នៅកាច់ជ្រុងផ្លូវ១៣ និង១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងអាចផ្លាស់ប្តូរទីកន្លែងបាន តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**ប.ក.** ជានីតិបុគ្គលមានស្វ័យភាពបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ។

**ប.ក.** ជាប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍ ដែលកំណត់ដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

**ប.ក.** ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្ម ស្របតាមកម្មវត្ថុរបស់ខ្លួន។

**ប.ក.** មានភារកិច្ច និងសិទ្ធិដូចខាងក្រោម ៖

១-អភិវឌ្ឍវិស័យប្រៃសណីយ៍ ក្នុងនិងក្រៅប្រទេស ដើម្បីបម្រើប្រជាពលរដ្ឋគ្រប់រូបដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និន្នាការនយោបាយ និងសាសនា។

២-បម្រើសេវា ទទួល ប្រមូល ដឹកជញ្ជូន និងបែងចែក រាល់បញ្ញើសំបុត្រប្រៃសណីយ៍គ្រប់ប្រភេទ បញ្ញើប្រៃសណីយ៍ភណ្ឌ និងបញ្ញើឆាប់រហ័ស ក្នុងនិងក្រៅប្រទេស។

៣-បម្រើសេវា ទទួល និងបែងចែក រាល់វិក្កយបត្ររបស់ស្ថាប័នរដ្ឋ ក្រុមហ៊ុន និងអង្គការនានាតាមកិច្ចព្រមព្រៀង។

៤-លក់តែមប្រៃសណីយ៍នៅតាមបញ្ជរ ឬនៅតាមទីភ្នាក់ងារ និងភ្នាក់ងារប្រៃសណីយ៍ ក្នុងនិងក្រៅប្រទេស។

៥-លក់សម្ភារៈ ឬផលិតផលផ្សេងៗ សម្រាប់បម្រើវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍។

៦-បម្រើសេវាបញ្ជូនព័ត៌មានតាមរូបភាពទូរគមនាគមន៍ និងតាមប្រព័ន្ធបណ្តាញផ្សេងៗទៀតទៅតាមការរីកចម្រើន របស់វិស័យទូរគមនាគមន៍ និងព័ត៌មានវិទ្យា។

៧-បម្រើសេវាហិរញ្ញវត្ថុប្រៃសណីយ៍។

៨-បម្រើសេវាធនាគារប្រៃសណីយ៍។

៩-កសាងតារាងតម្លៃសេវាប្រៃសណីយ៍ ក្នុងនិងក្រៅប្រទេស។

១០-បង្កើតសាខាប្រៃសណីយ៍នានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

១១–ទទួលសិទ្ធិបោះពុម្ពតែមប្រៃប្រៃសណីយ៍ និងផលិតសម្ភារៈផ្សេងៗទៀតសម្រាប់បម្រើវិស័យប្រៃសណីយ៍។

១២–ទទួលសិទ្ធិប្រើប្រាស់ម៉ាស៊ីនតែមប្រៃប្រៃសណីយ៍ សម្រាប់បម្រើវិស័យប្រៃសណីយ៍។

១៣–សហការជាមួយក្រុមហ៊ុន ឬស្ថាប័ន ក្នុងនិងក្រៅប្រទេស ក្នុងការធ្វើអាជីវកម្មប្រៃសណីយ៍។

១៤–អាចជួលទីកន្លែងសាធារណៈ ឬលំនៅឋានឯកជន ដើម្បីធ្វើទីតាំងស្នាក់ការប្រៃសណីយ៍តាមសមត្ថកិច្ចរបស់ខ្លួន និងដំឡើងប្រអប់សំបុត្រសាធារណៈនៅលើចិញ្ចើមថ្នល់ និងទីធ្លាសាធារណៈក្នុងករណីចាំបាច់។

១៥–អាចចុះកិច្ចសន្យាជួលជំនាញការ តម្រូវតាមសេចក្តីត្រូវការជាក់ស្តែង។

១៦–អាចចុះកិច្ចសន្យាខ្ចីទុនពីប្រភពផ្សេងៗ ដើម្បីយកមកវិនិយោគបន្ថែម ក្នុងករណីមានការយល់ព្រមពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៧–បម្រើសេវាប្រៃសណីយ៍ផ្សេងៗទៀតទៅតាមការរីកចម្រើនរបស់វិស័យប្រៃសណីយ៍។

១៨–ទទួលភារកិច្ច និងសិទ្ធិផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៣.–**

**ប.ក.** ត្រូវស្ថិតនៅក្រោមរបបនីតិរួមចំពោះពន្ធ និងអាករ ស្របតាមច្បាប់ និងបទបញ្ញាជាធរមាន។

**មាត្រា៤.–**

ដើមទុនដំបូងរបស់ **ប.ក.** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាព ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ពេលអនុក្រឹត្យនេះចូលជាធរមាន **ប.ក.** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ដែលរដ្ឋបានប្រគល់ឱ្យ ហើយដែលបានកត់ត្រាច្បាស់លាស់ ក្នុងបញ្ជីសារពើភណ្ឌ។

**មាត្រា៥.–**

បុគ្គលិករបស់**ប.ក.** ត្រូវជ្រើសរើសពីចំណោមមន្ត្រីនៃមុខងារសាធារណៈ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអាចជ្រើសរើសបន្ថែមតាមកិច្ចសន្យា ក្នុងករណីចាំបាច់។ បុគ្គលិករបស់ **ប.ក.** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលសម្រេច ដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា៦.–**

**ប.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិពេញលេញ ដើម្បីបំពេញការងារក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| -តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | ប្រធាន |
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| -អគ្គនាយក **ម.ត.** | ១រូប | សមាជិក |
| -តំណាងនិយោជិតរបស់ **ម.ត.** | ១រូប | សមាជិក។ |

**មាត្រា៧.-**

តំណាងរបស់រដ្ឋជាសមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើសដោយផ្អែកលើគុណសម្បត្តិនិងបទពិសោធន៍របស់ខ្លួនឬមួយពីក្នុងចំណោមមន្ត្រីរាជការបម្រើការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំ ឬចូលនិវត្តន៍តែមានអាយុមិនលើសពី៦៥ឆ្នាំ ឬមួយពីក្នុងចំណោមឥស្សរជនខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ចខាងនីតិសាស្ត្រឬខាងវិទ្យាសាស្ត្រ ។

តំណាងទាំងនោះ អាចឱ្យរួចផុតពីការបង់ប្រាក់ធានាសម្រាប់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល តែមិនត្រូវមានភាគហ៊ុនក្នុង **ម.ត.** ឡើយ។

សមាជិកក្រុមប្រឹក្សាភិបាល មិនត្រូវមានមុខរបរដែលអាចធ្វើឱ្យមានជម្លោះផលប្រយោជន៍ ដោយផ្ទាល់ជាមួយ **ម.ត.** ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យ សម្រាប់អាណត្តិ ០៣(បី)ឆ្នាំ។ អាណត្តិនេះអាចបញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់ក្រសួង ឬអង្គភាពដែលខ្លួនតំណាងឱ្យ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមនិយោជិតរបស់ **ម.ត.** ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសម្រេចក្នុងនាម **ម.ត.** លើលិខិតស្នាមឯកសារផ្សេងៗទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន។

ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ ៖

១-សម្រេចលើគោលដៅ យុទ្ធសាស្ត្រ និងគោលនយោបាយដើម្បីឱ្យ **ម.ត.** អនុវត្ត។

២-សម្រេចលើសេចក្តីស្នើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សម្រាប់បុគ្គលិកដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន។

៣-ផ្តល់ការយល់ព្រមលើគម្រោងផែនការដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ។

៤-វាយតម្លៃរៀងរាល់ពេល លើលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការ ដើម្បីកែសម្រួលឱ្យបានសមស្របតាមសភាពការណ៍។

៥-ផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពរបស់ **ម.ត**។

៦-សម្រេច បង្កើត បើក ឬបិទការិយាល័យ និងស្នាក់ការគ្រប់ទីកន្លែងរបស់ **ម.ត.** តាមការវិនិច្ឆ័យរបស់ខ្លួន។

៧-សម្រេចលើកិច្ចសន្យា និងកិច្ចព្រមព្រៀងដែល ម.ត. ជាភាគីហត្ថលេខី ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានក្នុងបទបញ្ញាជាធរមាន។

៨-សម្រេចលើការប្រើប្រាស់ប្រាក់ចំណេញរបស់ ម.ត. ស្របតាមលក្ខន្តិកៈរបស់ ម.ត. ។

៩-សម្រេចលើការដេញថ្លៃ លក់ ទិញ ជួលអចលនទ្រព្យ ចលនទ្រព្យដោយមានការឯកភាព ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១០-សម្រេចលើការជួលជំនាញការ តម្រូវតាមសេចក្តីត្រូវការជាក់ស្តែង។

**មាត្រា៩.-**

ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំនៅពេលណាក៏បាន អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសេចក្តីស្នើនៃសមាជិកភាគច្រើន ក្នុងចំណោមសមាជិកទាំងអស់។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិចមួយដង ក្នុងរយៈពេល ០៣(បី) ខែ ។

ករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលដែលមានវត្តមានដើម្បីដឹកនាំការប្រជុំ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខណ្ឌរបស់ខ្លួន។ របៀបវារៈនៃការប្រជុំព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវចែកជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច១០(ដប់)ថ្ងៃ មុនពេលបើកអង្គប្រជុំ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកភាគច្រើន។ ប្រសិនបើមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ១៥(ដប់ប្រាំ)ថ្ងៃក្រោយតទៅទៀត ដើម្បីពិភាក្សាបញ្ហាតាមរបៀបវារៈដដែល។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ។

សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ។ ប្រសិនបើសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព។

**មាត្រា១០.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយដែលត្រូវបញ្ជូន ទៅក្រសួងអាណាព្យាបាល សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋព្រមទាំងស្ថាប័នដទៃទៀត ដូចមានចែងក្នុងមាត្រា២២នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ យ៉ាងយូរចាប់ពីថ្ងៃប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រហូរហែ និងមានអត្តលេខចំណាំត្រឹមត្រូវ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធានអង្គប្រជុំ សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលវត្តមាន និងលេខាធិការជ្រើសរើសដោយអគ្គនាយក។

**មាត្រា១១.-**

អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារនៃ **ប.ត.** ជាប្រក្រតី និងត្រូវបានតែងតាំងសម្រាប់អាណត្តិ៣ (បី)ឆ្នាំ ដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ តំណែងនេះអាចបន្តទៅទៀតបាន តាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា១២.-**

ក្រុមប្រឹក្សាភិបាលត្រូវណែនាំ និងប្រគល់ឱ្យអគ្គនាយក នូវអំណាចចាំបាច់ទាំងឡាយសម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់។

អគ្គនាយកមានភារកិច្ចៈ

១-រៀបចំឯកសារទាំងឡាយដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច ចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនីមួយៗ និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ **ប.ត.** ។

២-ដឹកនាំ **ប.ត.** លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-ជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងគ្រប់គ្រងបណ្តាភ្នាក់ងារ ឬបុគ្គលិកគ្រប់រូប ដែលជានិយោជិតរបស់**ប.ត.** ដោយគោរពតាម លក្ខន្តិកៈក្រុមហ៊ុន លក្ខន្តិកៈបុគ្គលិក ឬច្បាប់ជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

៤-ផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រី ដែលនៅក្រោមឱវាទស្របតាមលក្ខខណ្ឌដែលបានកំណត់ ដោយក្រុមប្រឹក្សាភិបាល។

៥-ធ្វើជាតំណាងឱ្យ **ប.ត.** និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់ តវ៉ាការពារក្តីឱ្យ **ប.ត.** និងប្តឹងជំទាស់ផ្សេងៗ។

**មាត្រា១៣.-**

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសេចក្តីស្នើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា១៤.-**

ការចុះ និងអនុវត្តកិច្ចសន្យាដោយ**ប.ត.** ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន។

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១៥.-**

**ប.ត.** កាន់កាប់គណនេយ្យរបស់ខ្លួនឱ្យបានសមស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃ

គណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖

- ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់ នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល
- របាយការណ៍ហិរញ្ញវត្ថុ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣១ ខែមីនា នៃការិយបរិច្ឆេទបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុ ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេលមិនលើសពី១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ។ ឯកសារទាំងនោះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៦នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

**មាត្រា១៦.-**

រៀងរាល់ឆ្នាំ មុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការប្រចាំឆ្នាំរបស់**ម.ត.** តាមសេចក្តីស្នើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៧.-**

ធនធាននៃ **ម.ត.** មានជាអាទិ៍៖

- ដើមទុនដែលរដ្ឋផ្តល់ឱ្យ ( តុល្យការដំបូងនៅពេលបង្កើត )
- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យបន្ថែម
- ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពសេវាកម្មរបស់ **ម.ត.**
- ប្រាក់បានមកពីការលក់ ឬជួលចលនវត្ថុ និងអចលនវត្ថុរបស់ **ម.ត.**
- ប្រាក់បានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ។

**មាត្រា១៨.-**

ចំណាយនៃ **ម.ត.** រួមមាន ៖

- ចំណាយជាប្រក្រតីសម្រាប់ដំណើរការ
- ចំណាយវិនិយោគ
- ចំណាយសងបំណុល
- ចំណាយផ្សេងៗ។

**មាត្រា១៩.-**

**ម.ត.** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសម្រាប់តម្រូវការរបស់ខ្លួន។

**មាត្រា២០.-**

រៀងរាល់ឆ្នាំ ក្រោយពីមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់ចំណេញដែល **ម.ត.** ទទួលបានក្រោយពីមានការទូទាត់ស្របតាមវិធានគណនេយ្យដែលគេទទួលស្គាល់ជាទូទៅ ត្រូវបញ្ចូលទៅក្នុងគណនីធនបម្រុងស្របតាមលក្ខន្តិកៈរបស់ **ម.ត.** ។

ប្រាក់ចំណេញដែលនៅសល់បន្ទាប់ពីការទូទាត់ថ្លៃសរសើរ និងការបញ្ចូលក្នុងគណនីធនបម្រុងរួចមក ត្រូវបង់ចូលថវិកាជាតិទាំងអស់ ឬមួយផ្នែក ឬរក្សាទុកទាំងអស់ឱ្យសហគ្រាស ក្នុងករណីដែលរដ្ឋពិនិត្យឃើញថាការអភិវឌ្ឍជាការចាំបាច់។

**មាត្រា២១.-**

រដ្ឋធានាទូទាត់ជំនួស **ម.ត.** ចំពោះតែបំណុលណាដែលមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២២.-**

ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ម.ត.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ៖

-កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល

-គម្រោងផែនការ **ម.ត.**

-របាយការណ៍សកម្មភាព និងហិរញ្ញវត្ថុរបស់ **ម.ត.** ។

**មាត្រា២៣.-**

ត្រូវបានដាក់ឱ្យនៅអម **ម.ត.** មន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលតែងតាំងដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសម្លេងអនុម័តឡើយ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ និងមាត្រា២៥ នៃព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៩.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ